អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងធ្វើរ៉ាកែតចានស្នោរ**

**ចិត្តចលភាព៖** បំណិនចលនាធំ៖ ការហ្វឹកហាត់ បង្កើនកម្លាំង និងការសម្របសម្រួលនៃចលនាសាច់ដុំតូច និងសាច់ដុំធំ។

**សិក្សាសង្គម៖** គំនូរ និងសកម្មភាពកសាង៖ ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព។

**បុរេគណិត៖** ទំហំ និងពណ៌៖ ចំណាត់ក្រុម និងលំដាប់លំដោយ។

**គោលបំណង** ៖

**ចិត្តចលភាព៖** ប្រាប់បានពីរបៀបដើរ រត់ លោត វារលូន ចុះនិងឡើង បោះ តោង ឡើង គប់ រមៀល បង្វិលខ្លួន រុញ និងទាញ ទៅតាមគោលដៅ និងចម្ងាយដែលបានកំណត់។ គប់ចម្ងាយ គប់ចំណុច តោងឡើងរបារ បង្វិលខ្លួនលើដី និងជុំវិញរបស់មួយណា រុញ និងទាញដោយរាងកាយ។

**សិក្សាសង្គម៖** ប្រាប់បានពីការបត់រូបភាព រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់ … ដើម្បីបង្កើតជារូបភាពផ្សេងៗ។

បត់ក្រដាសបានជារូបផ្សេងៗដូចជា៖ យន្តហោះ ទូក អាវ…

**បុរេគណិត៖** ប្រាប់បានពីវត្ថុរៀបតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ចានក្រដាស ២ កន្ត្រៃ ស្កុត ដីខ្មៅពណ៌ ឈើការ៉េម២ ប៉ោងប៉ោង១។

**កម្រិតសិក្សា** ៖ មធ្យម និង ខ្ពស់

**ការរៀបចំ** ៖ គ្មាន

**សេក្តីណែនាំ៖**

1. ប្រាប់ក្មេងៗថា ពួកគេនឹងលេងល្បែងមួយដែលអាចធ្វើរ៉ាកែតចានក្រដាស ឬស្នោរក៏របាន។
2. សួរក្មេង តើកូនៗស្គាល់កីឡាវាយប៉េងប៉ុងដែរឬទេ? កូនៗចង់ធ្វើវាអត់? ចង់លេងវាអត់?
3. ចាប់ផ្តើមទាំងអស់គ្នា។
4. សម្ភាររួមមាន៖ ចានក្រដាស២ កន្ត្រៃ ស្កុត ដីខ្មៅពណ៌ ឈើការ៉េម២ ប៉ោងប៉ោង១
    - ដំបូងយកចានស្នោរទាំង២ ផាត់ពណ៌វាឱ្យបានស្អាត ជារូបអ្វីក៏បានដែរ តាមការស្រឡាញ់ចូលចិត្តរបស់ពួកគេ។
    - ប្រើស្កុតបិទឈើការ៉េមនៅពីខ្នងវាឱ្យបានរឹងមាំ។
    - ផ្លុំប៉ោងប៉ោងឱ្យមានទំហំល្មមសម្រាប់វាយទៅស្រួលក្នុងការលេងរបស់ពួកគេ។
    - សម្រាប់ការគូររូបភាពនៅក្នុងចានស្នោរនោះ បើមានរូបបកបិទគឺកាន់តែល្អបំផុត។

- ធ្វើប៉ុណ្ណឹងជាការស្រេចក្នុងការធ្វើរ៉ាកែតវាយសី។

5. ឱ្យក្មេងៗលេងវាយរ៉ាកែតចានស្មោរនោះជាមួយមិត្តរបស់គេគឺជាការស្រេចតែម្តងទៅតាមពេលវេលាដែលអ្នកបានកំណត់បានហើយ។
6. រ៉ាកែតមួយឈុតអាចលេងបាន២នាក់។